**សេចក្តីប្រកាសព័ត៌មាន**

**សមាជិកព្រឹទ្ធសភា** The Hon MARISE PAYNE
**រដ្ឋមន្ត្រីក្រសួងការបរទេសនៃប្រទេសអូស្ត្រាលី**

## សេចក្តីសម្រេចរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ប្រទេសអូស្ត្រាលី សូមស្វាគមន៍សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ក្នុងរាជធានីភ្នំពេញ នៅថ្ងៃនេះ។

នៅក្នុងសេចក្តីសម្រេច អ.វ.ត.ក បានសម្រេចផ្តន្ទាទោសអតីតមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម ខៀវ សំផន ជាអតីតប្រមុខរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យ និង នួន ជា ដែលជាអតីតអនុលេខាបក្សកុម្មុយនីស្តកម្ពុជា ពីបទប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ រួមមាន មនុស្សឃាត ការសម្លាប់រង្គាល ទាសករភាព ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភផ្លូវភេទនៅក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។

សេចក្តីសម្រេចនេះ គឺជាលើកដំបូងដែលតុលាការអន្តរជាតិបានកាត់ក្តីលើបទចោទប្រកាន់អំពីអំពើប្រល័យពូជសាសន៍ទាក់ទងនឹងរបបខ្មែរក្រហម។ ដំណើរការសវនាការនេះ មានសាធារណជនចូលរួមតាមដានប្រមាណ ៨៣.០០០នាក់។

សេចក្តីសម្រេចនៅថ្ងៃនេះ ធ្វើឡើងបន្ទាប់ពីមានការផ្តន្ទាទោស នួន ជា និង ខៀវ សំផន ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ទាក់ទងនឹងការជម្លៀសប្រជាជនដោយបង្ខំ និងការសម្លាប់ទាហាន និងការផ្តន្ទាទោស កាំង ហ្កេកអ៊ាវ ហៅឌុច ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម។

បង្កើតឡើងក្នុងឆ្នាំ២០០៣ អាណត្តិរបស់ អ.វ.ត.ក គឺដើម្បីទាមទារឲ្យមានការទទួលខុសត្រូវចំពោះអ្នកដែលប្រព្រឹត្តឧក្រិដ្ឋកម្មធ្ងន់ធ្ងរក្នុងសម័យខ្មែរក្រហម (១៩៧៥~១៩៧៩)។ ប្រជាពលរដ្ឋកម្ពុជាច្រើនជាង ១លាន៦សែននាក់បានស្លាប់ក្នុងអំឡុងពេលនៃការគ្រប់គ្រងរបស់ខ្មែរក្រហម។

អ.វ.ត.ក ក៏មានតួនាទីយ៉ាងសំខាន់ក្នុងការលើកកម្ពស់ការផ្សះផ្សាជាតិនៅកម្ពុជាដោយការចងក្រងកំណត់ត្រាលម្អិតនៃឧក្រិដ្ឋកម្មរបស់ខ្មែរក្រហម និងតាមរយៈយន្តការនានាដើម្បីទទួលស្គាល់ជនរងគ្រោះក្នុងរបបនេះ។

ប្រទេសអូស្ត្រាលី មានមោទនភាពក្នុងការផ្តល់ការគាំទ្រប្រកបដោយនិរន្តរភាព និងយូរអង្វែងដល់អាណត្តិដ៏សំខាន់របស់ អ.វ.ត.ក។ ចាប់តាំងពីឆ្នាំ២០០៥មក ប្រទេសអូស្ត្រាលី បានគាំទ្រថវិកាជាង៥០លានដុល្លារអូស្ត្រាលីដល់តុលាការខ្មែរក្រហម និងបានក្លាយជាជាម្ចាស់ជំនួយអន្តរជាតិធំទី៣។

ការគាំទ្ររបស់ប្រទេសអូស្ត្រាលីចំពោះ អ.វ.ត.ក ឆ្លុះបញ្ចាំងអំពីការប្តេជ្ញាចិត្តដ៏រឹងមាំរបស់អូស្ត្រាលីចំពោះយុត្តិធម៌ឧក្រិដ្ឋកម្មអន្តរជាតិ និងការការពារសិទ្ធិមនុស្ស។